**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**


MINISTRY OF ECONOMY AND FINANCE

**ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**
**ក្រុមការងារគ្រប់គ្រងគម្រោងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន**
**សម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**


លេខ......០៨៤......

# សេចក្តីជូនដំណឹង

## ស្តីពី

## ការដាក់ឱ្យដំណើរការមុខងារតាមដាននិងត្រួតពិនិត្យស្ថានភាពប្រតិបត្តិការហិរញ្ញវត្ថុ និង ការអនុវត្តថវិកា នៅក្នុងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS)

ក្រុមការងារគ្រប់គ្រងគម្រោង FMIS សូមជូនដំណឹងដល់ឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលកំពុងប្រើប្រាស់ប្រព័ន្ធ FMIS ទាំងអស់ជ្រាបថា ក្រុមការងារបានរៀបចំ និង អភិវឌ្ឍរួចរាល់នូវមុខងារថ្មីសម្រាប់ការតាមដាន និង ត្រួតពិនិត្យប្រតិបត្តិការហិរញ្ញវត្ថុ និង ការអនុវត្តថវិកានៅក្នុងប្រព័ន្ធ FMIS ដែលអនុញ្ញាតឱ្យអ្នកប្រើប្រាស់ប្រព័ន្ធតាមដាន និង ត្រួតពិនិត្យអំពីស្ថានភាពនៃប្រតិបត្តិការដែលបានបង្កើតនៅក្នុងប្រព័ន្ធ ។ មុខងារនេះត្រូវបានបែងចែកជាពីរផ្នែកគឺ ១-ផ្នែកតាមដានស្ថានភាពប្រតិបត្តិការ និង ២-ផ្នែកត្រួតពិនិត្យការអនុវត្តថវិកា ។ ផ្នែកតាមដានស្ថានភាពប្រតិបត្តិការដែលបានបង្កើតក្នុងប្រព័ន្ធ FMIS អាចប្រើប្រាស់បាននៅគ្រប់ការដ្ឋានទាំងអស់របស់ប្រព័ន្ធ FMIS ទាំងក្រសួង-ស្ថាប័ន និង អង្គភាពថវិកានៅថ្នាក់កណ្តាល និង អង្គភាពនៅតាមរាជធានី-ខេត្ត ។ សម្រាប់ផ្នែកត្រួតពិនិត្យការអនុវត្តថវិកា ដាក់ឱ្យអនុវត្តជំហានដំបូងតែសម្រាប់ថ្នាក់ដឹកនាំកម្រិតអគ្គនាយដ្ឋាននៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង ក្រសួងបរិស្ថានប៉ុណ្ណោះក្នុងសិទ្ធិជាអាណាប័ក និង អភិបាលហិរញ្ញវត្ថុ ស្របគ្នាជាមួយនឹងជំហាននៃការដាក់ឱ្យអនុវត្តនីតិវិធីសម្រាប់ការចំណាយថវិកាចរន្តតាមប្រព័ន្ធ FMIS ទាំងស្រុង ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម ឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលកំពុងប្រើប្រាស់ប្រព័ន្ធ FMIS ទាំងអស់មេត្តាជ្រាប និង អាចប្រើប្រាស់មុខងារខាងលើចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ថ្ងៃ សុក្រ ១៤ កើត ខែ ជេស្ឋ ឆ្នាំ ខាល ចត្វាស័ក ព.ស. ២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ ២០២៣

**រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី រដ្ឋលេខាធិការ**
**និង ជាប្រធានក្រុមការងារគ្រប់គ្រងគម្រោង FMIS**

បណ្ឌិតសភាចារ្យ **ហ៊ាន សាហ៊ីប**